មើលវីដេអូ ភាគទី ២០

# ការរួបរួមចេតសិក ចូលជាមួយនឹងចិត្ត

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# ចិត្តមាន៤ប្រភេទគឺ

១-កាមាវចរចិត្ត ៥៤ ដួង

២-រូបាវចរចិត្ត ១៥ ដួង

៣-អរូបាវចរចិត្ត ១២ ដួង

៤-លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង

សរុបត្រូវជា ៨៩ ដួង ឬ ១២១ ដួង

# កាមាវចរចិត្ត ៥៤ ចែកជា ២ ប្រភេទ

១- អសោភណចិត្តមាន ៣០ ដួង

២- សោភណចិត្តមាន ២៤ ដួង




អកុសលចិត្ត ១២ ដួង
Immoral Consciousness
លោភមូលចិត្ត ៨ ដួង
ទោសមូលចិត្ត ២ ដួង
មោហមូលចិត្ត ២ ដួង

# លោភមូលចិត្ត ៨ ដួង

## Consciousness Rooted in Attachment

**១-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ**

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ(មិច្ឆាទិដ្ឋិទាំងអស់) មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ។

Consciousness, unprompted, accompanied by pleasure, and connected with wrong view.

# ១- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ១៩ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក: ៤
- លោតិក: ២ គឺ លោភោ និង ទិដ្ឋិ (វៀរមានៈ)



## ២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ ។

Consciousness, prompted, accompanied by pleasure, and connected with wrong view.

# ២- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ២១ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោភិកៈ ២ (វៀរមានៈ)
- ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ



## ៣- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Consciousness, unprompted, accompanied by pleasure, and disconnected with wrong view.

# ៣- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ១៩ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោតិកៈ ២ គឺ លោភៈ និង មានៈ ( វៀរទិដ្ឋិ )



## ចំណាំ

លោភមូលចិត្ត ប្រការទី ៣ នេះមានចេតសិកប្រកបជាមួយ ១៩ ប្រភេទ តែក្នុងកាលណាដែលមានមានៈចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹមតែ ១៨ ប្រភេទប៉ុណ្ណោះក្នុងកាលណាដែលមិនមានមានៈចេតសិកកើតរួមជាមួយ។

## ៤-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

Consciousness, prompted, accompanied by pleasure, and disconnected with wrong view.

# ៤- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ២១ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោតិកៈ ២ ( វៀរទិដ្ឋិ )
- ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ



## ចំណាំ

- **លោភមូលចិត្តដួងទី ៤** នេះមានចេតសិកប្រកបជាមួយ ២១ ប្រភេទក្នុងកាលណាដែលមានមានៈចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹមតែ ២០ ប្រភេទប៉ុណ្ណោះ ក្នុងកាលណាដែលមិនមានមានៈចេតសិកកើត រួមជាមួយ។

- **មានៈ**និង**ទិដ្ឋិ** កើតរួមគ្នាមិនបានទេ ប៉ុន្តែនៅក្នុងកងអកុសលដូចគ្នា។